# បាឋកថាស្ដីពី
# គោលនយោបាយពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់
# វិស័យអប់រំ យុវជន និងកីឡា

ថ្លែងដោយឯកឧត្ដមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា
២៣ តុលា ឆ្នាំ ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ

# មាតិកា

- **ទី១** ៖ យុទ្ធសាស្ត្របញ្ញាកោណ ដំណាក់កាលទី១
- **ទី២** ៖ គោលនយោបាយ និងអាទិភាពកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាឆ្នាំ២០២៣-២០២៨
- **ទី៣** ៖ ស្តង់ដាសាលារៀនគំរូ ពានរង្វាន់សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី ។



# ផ្នែកទី១

# យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

# យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១

រាជរដ្ឋាភិបាលបានដាក់ចេញនូវ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព សំដៅ ការពារ ថែរក្សា និង ពូនជ្រុំ សមិទ្ធផលជាតិ, លើកកម្ពស់កិត្យានុភាពជាតិឱ្យខ្ពស់ត្រដែត, ជំរុញសម្ទុះនៃកំណើនសេដ្ឋកិច្ច, និងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាន ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០។ អាទិភាពគន្លឹះ ៥ គឺ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

# បញ្ចកោណទី១ ៖ ការអភិវឌ្ឍធនធានមនុស្ស

(១) ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

(២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

(៣) ការលើកកម្ពស់សុខភាព និង សុខុមាលប្រជាជន

(៤) ការពង្រឹងប្រព័ន្ធគាំពារសង្គម និង ប្រព័ន្ធស្បៀង

(៥) ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

# មុំទី១ ៖ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា

១) ការបន្តពង្រឹងគុណភាពអប់រំ និងការបណ្តុះបណ្តាលគ្រប់កម្រិត, ការធ្វើបច្ចុប្បន្នកម្មកម្មវិធីសិក្សានៅគ្រប់កម្រិត, និង ការបង្កើតបរិយាកាសល្អសម្រាប់ការសិក្សាពេញមួយជីវិត

២) ការបន្តកែទម្រង់សាលារៀន ដោយផ្តោតលើការពង្រឹងសមិទ្ធផលដែលមានស្រាប់, ការជំរុញការបង្កើតសាលារៀនជំនាន់ថ្មី និងសាលាគំរូ, ការពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពគ្រប់គ្រងនៅមន្ទីរអប់រំ យុវជន និងកីឡា, ព្រមទាំងការជំរុញការចូលរួម និងភាពជាម្ចាស់របស់មាតាបិតា, សហគមន៍ និងវិស័យឯកជន

៣) ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងវិធីសាស្ត្របង្រៀន ព្រមទាំងការបន្តលើកកម្ពស់ ជីវភាព និង គុណតម្លៃ បុគ្គលិកសិក្សាគ្រប់កម្រិត

# មុំទី១ ៖ ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

៤) ការបន្តលើកកម្ពស់ការអប់រំឌីជីថល, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលតាមសាលារៀន, និងការជំរុញនូវការចាប់យកមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEAM)

៥) ការលើកកម្ពស់សុខភាពសិក្សា និង ការបង្កើនអាហារូបករណ៍សម្រាប់សិស្ស-និស្សិតក្រីក្រ និងរងគ្រោះ។

៦) ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា; ការលើកកម្ពស់ការស្រាវជ្រាវ, ការអភិវឌ្ឍ និងការនវានុវត្តន៍; និង ការជំរុញភាពជាដៃគូរវាងរដ្ឋ និង ឯកជន

៧) ការលើកកម្ពស់វិស័យកីឡាផ្សារភ្ជាប់នឹងការអប់រំ និង ការបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"។

# អនុសាសន៍របស់
# សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងកិច្ចប្រជុំដំបូងគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧

(ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣)

# អនុសាសន៍បួនចំណុច

ទី១) ការពង្រឹងអភិបាលកិច្ចសាលារៀន

ទី២) ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និង ឥរិយាបថរបស់សិស្ស

ទី៣) ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភ ដល់កុមារ និងការត្រួតពិនិត្យ គុណភាពចំណីអាហារនៅតាមសាលា

ទី៤) ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និង សហគមន៍ ដើម្បីការអប់រំ។



# ផ្នែកទី២៖ គោលនយោបាយ និងអាទិភាព កំណែទម្រង់វិស័យអប់រំ យុវជន និងកឡាឆ្នាំ២០២៣-២០២៨

គំនូរបុរាណ ដោយ
លោកជៀត្រ ចន

# ការទទួលខុសត្រូវ និងការពង្រឹងប្រព័ន្ធអប់រំ



**ក្រសួងអប់រំ យុវជននិងកីឡាបានដាក់ចេញនូវគោលបំណងនៃការអប់រំជាតិ ៖**

1) បណ្តុះមនសិកាស្នេហាជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមោទនភាពជាតិ តាមរយៈការលើកកម្ពស់ការប្រកាន់នូវគំនិត គុណតម្លៃ បំណងប្រាថ្នារួមគ្នា ដើម្បីបង្កើតបាននូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ។
2) ផ្តល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មារតី។
3) ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិន និងសមត្ថភាព ដែលស្របទៅតាមតម្រូវការទីផ្សារការងារសម្រាប់សេដ្ឋកិច្ចពុទ្ធិប្រកបដោយពិពិធភាព ដែលអាចប្រកួតប្រជែងនៅថ្នាក់តំបន់ និងសកលលោក។
4) រៀបចំអ្នកសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចចូលរួមក្នុងពិភពលោក ដែលមានទំនាក់ទំនងជាមួយគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមក និងអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ដើម្បីបង្កើតនូវពិភពលោកមួយឱ្យកាន់តែមានសុខសន្តិភាព និងប្រកបដោយចីរភាព។

# អាទិភាពស្នូលទី១
# ការពង្រឹងអភិបាលកិច្ចសាលារៀន

# កំណែទម្រង់ថ្នាក់ជាតិ

- ផ្តោតលើ "ការពង្រឹងសមត្ថភាពចំណេះដឹង, សុខភាព និងឥរិយាបទដល់សិស្សគ្រប់រូប" លើការអប់រំចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ
- រៀបចំ "យន្តការថ្នាក់ជាតិដើម្បីជំរុញកំណែទម្រង់" តាមរយៈការកំណត់អាទិភាព បញ្ហាប្រឈម យុទ្ធសាស្ត្រ និងពង្រឹងការពិនិត្យតាមដាននិងវាយតម្លៃ
- រៀបចំ "ក្រុមការងារបច្ចេកទេសកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា" និង "ក្រុមចុះជួយ coaching team" រួមជាមួយនាយកសាលាល្អចូលនិវត្តន៍ ដើម្បីចុះជួយគាំទ្រនៅតាមសាលារៀន
- ផ្សព្វផ្សាយ "ឧត្តមមានុវត្តន៍នៃកំណែទម្រង់សាលារៀន" ដូចជាសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ ឱ្យបានទូលំទូលាយទូទាំងប្រទេស

# កំណែទម្រង់ថ្នាក់ជាតិ

- គាំទ្រចំពោះការចូលរួមក្នុង "វង្វាយតម្លៃការសិក្សាកម្រិតអន្តរជាតិ (PISA)" ដើម្បីលើកកម្ពស់ស្តង់ដានៃការអប់រំនៅកម្ពុជា និងរិះរកវិធានការកែលម្អ
- ប្រើប្រាស់លទ្ធផលវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ នៅថ្នាក់ទី៣, ទី៦, ទី៨, និងទី១១ ដើម្បីកែលម្អប្រព័ន្ធអប់រំ
- រៀបចំ"សេចក្តីណែនាំស្តីពី ការអនុវត្តតេស្តស្តង់ដានៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា" និង "ឯកសារស្តីពី ការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស" ដើម្បីលុបបំបាត់ការយកកិច្ចការរៀនគួរទៅដាក់សម្ពាធលើសិស្សមិនរៀនគួរ
- ពិនិត្យឡើងវិញ និងរៀបចំ "ស្តង់ដាសាលារៀន ស្តង់ដាសាលាគំរូ និងសាលារៀនជំនាន់ថ្មី"
- រៀបចំ "ប្រព័ន្ធព័ត៌មានសាលារៀន" ដើម្បីគ្រប់គ្រងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ។

# កំណែទម្រង់កម្រិតសាលារៀន

- **កម្រិតមត្តេយ្យសិក្សា៖** ពង្រឹងសាលាមត្តេយ្យដែលមានស្រាប់ ដោយមិនពង្រីកបន្ថែម និងផ្តោតលើមត្តេយ្យសហគមន៍ជា និងការបណ្តុះបណ្តាលគ្រូមត្តេយ្យឱ្យមានគុណភាពជាពិសេស មត្តេយ្យសិក្សាសហគមន៍។
- **កម្រិតបឋមសិក្សា៖** ផ្តោតលើកញ្ចប់អំណានដំបូង និងគណិតវិទ្យាថ្នាក់ដំបូង, ការបង្រៀនភាសាបរទេស, ការដោះស្រាយកង្វះគ្រូនៅតំបន់ជួបការលំបាក, សុខភាពនិងអាហារូបត្ថម្ភរបស់សិស្ស និងភាពក្រីក្រ។
- **កម្រិតមធ្យមសិក្សា៖** ពង្រីកអនុវិទ្យាល័យ និងវិទ្យាល័យនៅនឹងកន្លែង ស្របតាមត្រូវការរបស់ប្រជាជន ។
- **កម្រិតឧត្តមសិក្សា៖** ពង្រឹងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងប្រើប្រាស់យន្តការនៃបណ្តាញវិស័យឯកជន ក្នុងការចូលរួមវាយតម្លៃ និងធានាគុណភាពអប់រំនៅឧត្តមសិក្សា

# កំណែទម្រង់កម្រិតសាលារៀន

កំណែទម្រង់កម្រិតសាលារៀន

- **បន្តធ្វើកំណែទម្រង់សាលារៀន** ៖ ផ្តោតជាសំខាន់លើ "សាលារៀនគំរូ" ដោយពង្រឹងសាលារៀនគំរូដែលមានស្រាប់ និងពង្រីកសាលារៀនធម្មតាឱ្យក្លាយជាសាលារៀនគំរូតាមរយៈការដាក់ឱ្យអនុវត្តទូទៅសម្រាប់សាលារៀនទាំងអស់
- **អនុវត្ត "វិធីសាស្ត្របង្រៀនថ្មី"** ដូចជាការបង្រៀនតាមបែបគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ។ល។ ដែលបានដាក់ឱ្យអនុវត្តនៅសាលារៀនជំនាន់ថ្មី
- **ជំរុញ និងលើកទឹកចិត្តដល់ "ការបង្រៀននិងរៀនមុខវិជ្ជាស្ទែម"** ដោយបង្កើតគណៈកម្មការសម្រាប់ការលើកកម្ពស់វិធីសាស្ត្របង្រៀនមុខវិជ្ជាស្ទែម និងជួយគាំទ្រដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ, ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា និងគ្រូឆ្នើមផ្នែកស្ទែម ដើម្បីរៀបចំឯកសារ ចងក្រងវិធីសាស្ត្របង្រៀនល្អៗ
- **រៀបចំ "បណ្ណាល័យស្តង់ដា"** ដោយសហការជាមួយអង្គការដៃគូ និងផ្តោតលើសាលារៀនគំរូ

# កំណែទម្រង់កម្រិតសាលារៀន

កំណែទម្រង់កម្រិតសាលារៀន

- ពង្រឹង "**ការបណ្តុះបណ្តាលនាយក និងការតែងតាំងនាយក**" ព្រមទាំងការត្រួតពិនិត្យ និងការវាយតម្លៃការងាររបស់នាយក ផ្អែកតាមស្តង់ដាអប្បបរមា និងការលើកទឹកចិត្តនាយកមានស្នាដៃ និងការអនុវត្តគន្លងអាជីពនាយក
- **រៀបចំ "យន្តការចុះកិច្ចសន្យាការងារប្រចាំឆ្នាំរវាងនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន"**
- **ត្រួតពិនិត្យវត្តមានសិស្ស និងវត្តមានគ្រូបង្រៀន** ព្រមទាំងការពង្រឹងការអនុវត្តម៉ោងសិក្សា
- **រៀបចំ "វិធានការ និងយន្តការដើម្បីជួយសិស្សរៀនយឺត"** ដូចជា ស្វ័យសិក្សាតាមមេរៀន ជំរុញគ្រូបង្រៀនឱ្យដាក់កិច្ចការសិស្ស រៀបចំក្លឹបសិក្សាតាមមុខវិជ្ជា
- **រៀបចំផែនការ "អធិការកិច្ចថ្នាក់រៀន"** ប្រចាំខែ និងចុះអធិការកិច្ចជួយគ្រូឱ្យច្បាស់លាស់
- **ធ្វើ "អធិការកិច្ចតាមមុខវិជ្ជា និងធ្វើអធិការកិច្ចតាមប្រធានបទ"** ដោយផ្តោតលើការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀន និងផ្តោតលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា។

# ប្រភេទទី១ សាលារៀនជំនាន់ថ្មី

## ទម្រង់នៃកំណែទម្រង់សាលារៀន

- **ប្រភេទទី១ សាលារៀនជំនាន់ថ្មី** គឺផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សា ដើម្បីបណ្តុះធនធានមនុស្សមានបំណិនសតវត្សទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមាន៖ ក).សីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់, ខ).គណនេយ្យភាព, នវានុវត្តន៍, គ).ចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការរៀន និងបង្រៀន, ឃ).ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី។ សិស្សសាលារៀនជំនាន់ថ្មីមាន៖ ក).ការផ្តួច ផ្តើមគំនិត និងសហគ្រិនភាព, ខ).ចេះទំនាក់ទំនង និងសរសេរយ៉ាងប៉ិនប្រសប់, គ).ចេះវិភាគវាយតម្លៃព័ត៌មាន, ឃ). ចង់ឃើញ ចង់ដឹង និងមានការស្រមើលស្រមៃ, ច). ចេះគិតបែបវិភាគស៊ីជម្រៅ និងការដោះស្រាយបញ្ហា, ឆ).ចេះសហការ, និងជ).មានភាពរហ័សរហួន និងចេះយកចំណេះដឹងទៅអនុវត្ត។

# ប្រភេទទី២ សាលារៀនគំរូ

ទម្រង់នៃកំណែទម្រង់សាលារៀន

- **ប្រភេទទី២ សាលារៀនគំរូ** គឺផ្តោតលើ ក).សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព, ខ).សាលារៀនមានស្វ័យភាព ក្នុងការងារផែនការកែលម្អ សាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន, គ).សិស្សត្រូវបាន ធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀន, ការជួយសិស្សរៀនយឺត, និងផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាល និងសហគមន៍, ឃ).គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ, ង).មាតាបិតា ឬអ្នកអាណាព្យាបាលនិងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀន។

# ប្រភេទទី២ សាលារៀនគំរូ

ទម្រង់នៃកំណែទម្រង់សាលារៀន

សាលារៀនគំរូ គឺជាសាលារៀន ដែលសម្រេចបាននូវ **ស្តង់ដាទាំង ៥** គឺ៖

- ស្តង់ដាទី១ ៖ លទ្ធផលសិក្សារបស់សិស្ស
- ស្តង់ដាទី២ ៖ ដំណើរការបង្រៀន និងរៀន
- ស្តង់ដាទី៣ ៖ ការចូលរួមរបស់សហគមន៍
- ស្តង់ដាទី៤ ៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន
- ស្តង់ដាទី៥ ៖ គណនេយ្យភាព

# ប្រភេទទី៣ សាលារៀនធម្មតា

ទម្រង់នៃកំណែទម្រង់សាលារៀន

- ប្រភេទទី៣ សាលារៀនធម្មតា គឺផ្តោតលើ ក).ការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សស្រប តាមការរកឃើញនៃលទ្ធផលតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៣ ទី៦ ទី៨ និងទី១១, ខ).ការពង្រឹងវត្តមានគ្រូ និងវត្តមានសិស្ស, គ).ការពង្រឹងការគ្រប់គ្រងតាមសាលារៀន ។
- បន្តពង្រឹងគុណភាព ដោយផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា (បំណិន វិជ្ជាជីវៈ និងទន់) ចរិយាសម្បទា (សីលធម៌ និងវិន័យ)
- ផ្តល់ការលើកទឹកចិត្តបន្ថែមចំពោះគ្រឹះស្ថានសិក្សានៅតាមតំបន់ដាច់ស្រយាល និងជួបការលំបាក ដោយបន្តសាងសង់ផ្ទះគ្រូ និង ផ្តល់ប្រាក់ឧត្ថម្ភឱ្យបានសមស្រប
- ដោះស្រាយបញ្ហាខ្វះគ្រូ ដោយអនុវត្តរូបមន្តពង្រឹង ៨០% ពង្រីក ២០%
- បន្តវិនិយោគលើការបង្កើតបណ្ណាល័យសតវត្សទី២១
- បន្តអភិវឌ្ឍវិទ្យាល័យអប់រំពិសេស។

# ការគ្រប់គ្រងគ្រឹះស្ថានសិក្សាឯកជន

- ជំរុញការអនុវត្តសេចក្ដីណែនាំស្ដីពី ការលើកកម្ពស់ការសិក្សាភាសាខ្មែរ និងវប្បធម៌អរិយធម៌ខ្មែរ នៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅឯកជនដែលអនុវត្តកម្មវិធីសិក្សាអន្តរជាតិ
- រៀងរាល់ថ្ងៃចន្ទមុនពេលចូលរៀន ត្រូវឱ្យសិស្សច្រៀងវគ្គទីមួយ នៃបទនគររាជ និងបទពង្សាវតាខ្មែរ
- ពិនិត្យ និងតាមដានលើការងារអនុវត្តកម្មវិធីសិក្សា និងដំណើរការប្រឡងនានា
- វាយតម្លៃការគ្រប់គ្រង និងដំណើការគ្រឹះស្ថានសិក្សាឯកជន មុននឹងសម្រេចបង្កើតបន្ថែម។

# ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- កំណត់កូតាសម្រាប់ "សិស្សនិទ្ទេស A, B, C ដើម្បីជ្រើសរើសចូលធ្វើគ្រូបង្រៀន" ដោយឆ្លងកាត់ការវាយតម្លៃទៅតាមលក្ខណៈវិនិច្ឆ័យដែលនឹងបានកំណត់ (អាចជ្រើសរើសផ្អែកតាមលំដាប់ពិន្ទុពេលប្រឡង)។ ដោយឡែក កូតានៅសល់សម្រាប់បេក្ខជនផ្សេងទៀតដោយត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសដូចធម្មតា ដែលនឹងដឹកនាំដោយក្រុមការងារថ្នាក់ជាតិ និងមានការចូលរួមពីសំណាក់តំណាងទីស្តីការគណៈរដ្ឋមន្ត្រី
- អនុវត្ត "វិធានការម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងគ្រូបង្រៀន និងបុគ្គលិកអប់រំ" ដោយទប់ស្កាត់មិនឱ្យមានករណីអន្តរាគមន៍
- រៀបចំ "រង្វាន់លើកទឹកចិត្តគ្រូល្អ និងនាយកល្អ" ដែលសម្រេចបានសមិទ្ធកម្មល្អប្រសើរតាមរយៈការរៀបចំជាប្រាក់លើកទឹកចិត្ត ប្រាក់តំបន់ជួបការលំបាក និងប្រាក់ស្នាដៃ។

# ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- រៀបចំការសិក្សា និងយន្តការ "ដោះស្រាយបញ្ហាលើស ខ្វះគ្រូ"
- ពិនិត្យឡើងវិញ "តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល" និងការពិនិត្យឡើងវិញការឧបត្ថម្ភសម្រាប់តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក
- រៀបចំ "ក្រុមការងារដឹកនាំកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ" និងរៀបចំ "ក្រុមការងារថ្នាក់ជាតិចុះជួយគាំទ្រសាលាគរុកោសល្យ",
- បន្តអនុវត្ត "ការប្រឡងប្រណាំងគ្រូល្អ នាយកល្អ" និងរៀបចំយន្តការវាយតម្លៃការអនុវត្តស្តង់ដាអប្បបរមាគ្រូបង្រៀន ស្តង់ដាអប្បបរមានាយកសលា ជាពិសេសការដោះស្រាយទិដ្ឋភាពអវិជ្ជមាននៃការបង្រៀនគួរ ការត្រួតពិនិត្យវត្តមាន និងការអនុវត្តកម្មវិធីសិក្សា

# ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

ការធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលផ្តោតលើ ៖

- ១) ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ ដើម្បីផ្តល់ឱ្យគរុនិស្សិតប្រតិបត្តិគុណសម្បទា និង បំណិនសតវត្សរ៍ទី២១ មានគុណវុឌ្ឍិអនុលោមតាម «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន» ដោយកំណត់ស្តង់ដាគុណវុឌ្ឍិ៖ (ក)១២+២=គ្រូមត្តេយ្យ (ខ) ១២+៤=គ្រូបឋម (គ) ១២+៤= គ្រូមមូលដ្ឋាន និង (ឃ) បរិញ្ញា+២=គ្រូឧត្តម
- ២) ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេស ផ្តោតលើ (ក) ខ្លឹមសារមេរៀន (ខ) គរុកោសល្យ ជាពិសេសវិធីសាស្ត្របង្រៀនសម្បូរបែប តាមបែបសកម្ម (គ) បច្ចេកវិទ្យា
- ៣) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាការបំពាក់បរិក្ខាររៀន និងបង្រៀនស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេស ឯកសាររៀននិងបង្រៀនទំនើប

# ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- ៤) ការអភិវឌ្ឍភាពជាអ្នកដឹកនាំគ្រប់គ្រង ដោយផ្តោតលើ (ក) ការគ្រប់គ្រងការរៀន និងបង្រៀន (ខ) ការគ្រប់គ្រងរដ្ឋបាល (គ) ការគ្រប់គ្រងហិរញ្ញវត្ថុ (ឃ) ការគ្រប់គ្រងបុគ្គលិក និងធនធាន
- ៥) ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ តាមរយៈការពង្រឹងគុណភាពកម្មសិក្សាគរុកោសល្យ
- ៦) ការធានាគុណភាព៖ ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង គណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ ការវាយតម្លៃឯករាជ្យ
- បង្កើនគុណភាពគ្រូឧទ្ទេស ដោយជ្រើសរើសចេញពីសាលាគរុកោសល្យ និងគ្រូល្អ ដើម្បីយកទៅបណ្តុះបណ្តាលបន្ត ព្រមទាំងអនុវត្តគន្លងជាជីព

# ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

– ធ្វើវិក្រឹតការគ្រូបង្រៀនលើវិធីសាស្រ្តបង្រៀននិងការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ឱ្យបានដល់គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ នៅទូទាំងប្រទេស
– បង្កើតយន្តការប្រឹក្សាគរុកោសល្យ សម្រាប់ការចុះគាំទ្រដល់គ្រូបង្រៀនកម្រិតថ្នាក់ដំបូង ដើម្បីធានាគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តកញ្ចប់ សម្ភារៈអំណាន និងគណិតវិទ្យា ថ្នាក់ដំបូង
– ធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន
– រៀបចំយន្តការដើម្បីអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

# ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- ជំរុញការអនុវត្តគោលនយោបាយមត្តេយ្យសិក្សា និងការផ្តល់ប្រឹក្សា
- ចាប់ផ្តើមបណ្តុះបណ្តាលគ្រូជំនាញអប់រំពិសេសលើផ្នែក គ ថ្លង់ ពិការភ្នែក និង សតិបញ្ញា នៅវិទ្យាស្ថានជាតិអប់រំពិសេស ដោយបណ្តុះជំនាញឯកទេសបន្ថែម១ឆ្នាំ (គ្រូកម្រិតបឋមសិក្សា (១២+២+១) និងគ្រូកម្រិតម.បឋមភូមិ (១២+៤+១) និងគ្រូកម្រិតម.ទុតិយភូមិ (១២+៤+១+១)
- ដាក់បញ្ចូលការបណ្តុះបណ្តាលគ្រូអប់រំពហុភាសា នៅមជ្ឈ.គរុ.ភូមិភាគខេត្ត ស្ទឹងត្រែង
- រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូជំនាញអប់រំពិសេសផ្នែក គ ថ្លង់ ពិការភ្នែក និងពិការសតិបញ្ញា និងពង្រឹងការស្រាវជ្រាវភាសាសញ្ញា និងអក្សរប្រៃយ៍ខ្មែរ ។

# ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

## ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- ១) បង្កើនចំនួនសាលារៀនជំនាន់ថ្មី, សាលារៀនគំរូ និងបង្កើនម៉ោងបង្រៀន និងការបង្រៀន ផ្តោតលើមុខវិជ្ជាស្ទែម
- ២) វិនិយោគបន្ថែម និងបង្កើនគុណភាពនៃការបណ្តុះបណ្តាលគ្រូមុខវិជ្ជាស្ទែមឱ្យដល់កម្រិតស្តង់ដារវិជ្ជាជីវៈ
- ៣) កែលម្អវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាស្ទែម ដោយផ្តោតលើវិធីវិទ្យាសាស្ត្រ, វិធីរិះរក, តាមបែបគម្រោង និងវិធីផ្សេងទៀត ព្រមទាំងបង្កើនម៉ោងបង្រៀន និងការបង្រៀន
- ៤) វិនិយោគបន្ថែមលើការបំពាក់សម្ភារៈឧបទេស និងជំរុញការធ្វើពិសោធន៍ នៅតាមសាលារៀនជំនាន់ថ្មី វិទ្យាល័យធនធាន សាលារៀនគំរូ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ៥) ជំរុញការបង្កើតក្លឹបសិក្សាក្រោយម៉ោងសិក្សា និងពង្រឹងក្រុមប្រឹក្សាយុវជន និងបង្កើតប្រព័ន្ធអេកូឡូស៊ី ដូចជាពិព័ណ៌វិទ្យាសាស្ត្រ និងពិព័ណ៌ស្នាដៃសិស្ស។

# ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធទន់ ដោយពង្រឹងគុណតម្លៃគណៈគ្រប់គ្រង និងគ្រូបង្រៀន និងកែប្រែវប្បធម៌សាលារៀន ការអនុវត្តគន្លងអាជីព និងការបណ្តុះបណ្តាលវិជ្ជាជីវជាប្រចាំ ការគ្រប់គ្រង ផ្តោតលើលទ្ធផល ទៅតាមកម្រិតនៃការវិនិយោគ
- ពិនិត្យទ្បើងវិញសៀវភៅគោល វិទ្យាសាស្ត្រនិងគណិតវិទ្យា, បណ្តុះបណ្តាលពីវិធីសាស្ត្រវិទ្យាសាស្ត្រ ,បំពាក់សម្ភារៈឧបទេសបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ, បណ្តុះបណ្តាលនិងកែលម្អពីការប្រើប្រាស់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ, ពង្រឹងការប្រើប្រាស់បណ្ណាល័យ និងកំណត់កាលវិភាគឱ្យសិស្សចូលបណ្ណាល័យ
- លើកកម្ពស់ការអប់រំបច្ចេកទេសស្របតាមស្តង់ដា (ចលនាប្រឡងប្រណាំង វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសល្អ)
- ផ្សារភ្ជាប់មធ្យមសិក្សាទៅនឹងឧត្តមសិក្សា តាមរយៈការផ្តល់ប្រឹក្សាអាជីព និងការលើកកម្ពស់ការបណ្តុះបណ្តាលបំណិនជីវិត នៅតាមគ្រឹះស្ថានមធ្យមសិក្សា
- បង្កើតក្លឹបសិក្សា៖ ក្លឹបសិក្សាសរសេរកូដ ការផលិតមនុស្សយន្ត រួមទាំងកម្មវិធីសិក្សា ដែលជាជំនាញទន់ជាច្រើនទៀត ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងសតវត្សទី២១ ។

# អានុភាពស្នូលទី២
# ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និង សកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវ ការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

# ការអប់រំចរិយាធម៌

ការអប់រំចរិយាធម៌ (Character Education) គឺជាអាទិភាពថ្មីសម្រាប់នីតិកាលទី៧ ដោយក្រសួងអប់រំ យុវជន និងកីឡានឹងដាក់ចេញវិធានការដូចតទៅៈ

- យកចិត្តទុកដាក់លើ "ការអភិវឌ្ឍផ្នែកទន់" ជាពិសេសការអនុវត្តកម្មវិធីសិក្សាឱ្យបានពី ៤ម៉ោង ទៅ ៦ម៉ោងក្នុង ១ថ្ងៃ (ឬ៤០ម៉ោងក្នុង១សប្តាហ៍) ដោយនៅសាលាបឋមសិក្សាផ្តោតលើអំណានដំបូង និងគណិតវិទ្យាដំបូង និងនៅអនុវិទ្យាល័យ និងវិទ្យាល័យផ្តោតលើវិធីសាស្ត្របង្រៀនថ្មី។ ក្រសួងនឹងបញ្ជ្រាប និងបញ្ចូលកម្មវិធីអភិវឌ្ឍយុវជនទូទៅនៅក្នុងសាលារៀន ដូចជាការអប់រំបរិស្ថាន អនាម័យស្អាត សីលធម៌ ។ល។ ដើម្បីកាត់បន្ថយពេលទំនេររបស់សិស្ស និងបង្កើតទម្លាប់ល្អរបស់សិស្ស
- រៀបចំ "កម្មវិធីអប់រំចរិយាធម៌" ដោយផ្តោតលើការចេះគោរពចាស់ទុំតាមរយៈការសំពះ ការស្លៀកពាក់ស្អាតបាត និងអនាម័យល្អ

# ការអប់រំចរិយាធម៌

- រៀបចំ "សេចក្តីណែនាំស្តីពី ការអប់រំចរិយាសម្បទា" ដោយដកស្រង់ពីមុខវិជ្ជាសីលធម៌ និងពលរដ្ឋវិទ្យា
- រៀបចំវិធានការ ដើម្បីលើកកម្ពស់ការយល់ដឹងពីវប្បធម៌ និងអារ្យធម៌ខ្មែរ ដូចជាការសំពះ និងឥរិយាបថល្អសម្រាប់កុមារ និងយុវជន
- ផ្តល់ពិន្ទុសិស្សផ្តោតលើចំណេះដឹងខាងផ្នែក៖ (១) វិជ្ជាសម្បទា (២) បំណិនសម្បទា និង (៣) ចរិយាសម្បទា"។ ការផ្តល់ពិន្ទុប្រចាំខែ និងប្រចាំឆ្នាំដល់សិស្ស នឹងរាប់បញ្ចូលនូវការចូលរួមក្នុងការងារសង្គម ការចូលរួមក្នុងក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន កម្មវិធីមិត្តជួយមិត្ត កម្មវិធីបង្រៀនសិស្សខ្សោយ ក្លឹបសិក្សា ការជួយដល់ការងារសហគមន៍ ការសម្អាតថ្នាក់រៀន បន្ទប់ទឹក សាលារៀន ការដាំដើមឈើ សួនបន្លែ ការលើកកម្ពស់បរិស្ថានសាលារៀនស្អាត ការងារស្វ័យសិក្សា ការហាត់កីឡាដើម្បីសុខភាព ការអប់រំប្រឆាំងការប្រើប្រាស់សារធាតុញៀន ការងារស្ម័គ្រចិត្ត។

# ការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១

– ក) កម្មវិធីអភិវឌ្ឍយុវជនទាំងបំណិនរឹង និងបំណិនទន់ ដោយផ្ដោតលើបំណិនសតវត្សទី ២១ និងលើកកម្ពស់ភាពជាអ្នកដឹកនាំ រួមមាន៖១).បំណិនត្រិះរិះពិចារណា, ២).នវានុវត្តន៍ និងដោះស្រាយបញ្ហា ៣).សហការ, ៤).ទំនាក់ទំនង និងប្រាស្រ័យទាក់ទង, ៥).អក្ខរកម្មព័ត៌មាន៖ យល់ពីព្រឹត្តិការណ៍ ទិន្នន័យ និងស្ថិតិ, ៦).អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ៖ ចេះបែងចែកព័ត៌មានសំខាន់ និង ព័ត៌មានក្លែងក្លាយ, ៧).អក្ខរកម្មបច្ចេកវិទ្យា៖ ចេះប្រើបច្ចេកវិទ្យា និងបន្សាំខ្លួនងាយស្រួល, ៨). ភាពទន់ភ្លន់៖ ចេះបន់បែនតាមសភាពការណ៍ដែលវិវត្តយ៉ាងលឿន, ៩).ភាពជាអ្នកដឹកនាំ៖ ធ្វើការលើសពីការរំពឹងទុក ចេះគ្រប់គ្រង និងដឹកនាំអង្គភាព មានគំនិតផ្ដួចផ្ដើម មានឥរិយាបថវិជ្ជមាន មានចក្ខុវិស័យ ផ្ដល់ការលើកទឹកចិត្ត មានការទទួលខុសត្រូវ តស៊ូពេលលំបាក ចេះស្ដាប់មតិយោបល់អ្នកដ៏ទៃ ចេះសម្រេចចិត្ត, ១០). ការមានគំនិតផ្ដួចផ្ដើម និងសហគ្រិនភាព, ១១). ផលិតភាព និង ១២). បំណិនសង្គម៖ មានបំណិនទំនាក់ទំនង

# ការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១

- ខ) ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ទាំងការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង បំណិនទន់ ដើម្បីឱ្យយុវជនមានសមត្ថភាពចូលរួមដោះស្រាយបញ្ហារួមរបស់ប្រទេសជាតិ, មានភាពក្លាហាន និងមានភាពឈ្លាសវៃក្នុងការបញ្ចេញមតិ, មានសមត្ថភាពត្រិះរិះពិចារណា សិក្សាស្រាវជ្រាវ ចែករំលែក គំនិត និងជំនាញក្នុងការនិយាយសាធារណៈ ប្រកបដោយក្រមសីលធម៌ និងចំណេះដឹងពិតប្រាកដ
- គ) ការផ្តល់ឱកាសឱ្យយុវជនបញ្ចេញគំនិតយោបល់, បង្ហាញទេពកោសល្យ ដើម្បីបង្កើតសង្គមពុទ្ធិ និង ស្វែងរកសុខដុមនីយកម្មសម្រាប់ទាំងអស់គ្នា, បង្កើតទំនាក់ទំនងល្អ រវាងយុវជននិងយុវជន និងលើកកម្ពស់តម្លៃមិត្តភាព

# ការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១

– ឃ) ការបង្កើតជាថ្នាលដោយផ្តោតលើបំណិនរឹង និងបំណិនទន់សម្រាប់យុវជនហាត់ការឱ្យមានភាព រឹងមាំ មានភាពចាស់ទុំគំនិត និងចេះគិតយ៉ាងហ្មត់ចត់ រួមមាន៖ ១).ការប្រកួតប្រជែង ព័ត៌មាន វិទ្យា, ២).ការប្រកួតប្រជែងផែនការអាជីវកម្ម, ៣).ការប្រកួតប្រជែងមនុស្សយន្ត, ៤).ការងារ ស្ម័គ្រចិត្ត, ៥).កាយវិទ្ធិ, និង៦).ការបោះជំរំ

– ង) ការបណ្តុះបណ្តាលយុវជនឱ្យចូលរួមដោះស្រាយបញ្ហារួមរបស់ប្រទេសជាតិ គាំទ្ររដ្ឋាភិបាល កសាងសមត្ថភាពយុវជនឱ្យមានភាពក្លាហាន មានភាពឈ្លាសវៃ, ពង្រឹងសមត្ថភាពត្រិះរិះ ពិចារណា សិក្សាស្រាវជ្រាវ ចែករំលែកគំនិត និងជំនាញក្នុងការនិយាយសាធារណៈ ប្រកបដោយក្រមសីលធម៌ និងចំណេះដឹងពិតប្រាកដ។

# អាទិភាពស្នូលទី៣

# ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្ត ទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធី អាហារូបត្ថម្ភដល់កុមារ និងការ ត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា

# ការលើកកម្ពស់សុខភាពសិក្សា

- បន្តអនុវត្ត "កម្មវិធីផ្តល់អាហារតាមសាលារៀន" ដែលជាផ្នែកមួយនៃការលើកកម្ពស់សុវត្ថិភាព សង្គម សមធម៌ សុខភាពសិក្សា ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ
- គិតគូរភាពជាម្ចាស់ និងនិរន្តរភាពរបស់កម្មវិធីផ្តល់អាហារតាមសាលារៀន អាស្រ័យលើលទ្ធភាពថវិកា
- បន្តអនុវត្ត"កម្មវិធីផ្តល់អាហារូបករណ៍ជាសាច់ប្រាក់"ដែលជាផ្នែកមួយនៃប្រព័ន្ធសុវត្ថិភាពសង្គម

# ការលើកកម្ពស់សុខភាពសិក្សា

– ក្នុងបរិបទនៃគន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ សាលារៀនត្រូវធានាបាននូវនិរន្តរភាពនៃដំណើរការ និងធានាសុវត្ថិភាពសុខភាព រួមទាំងសុខភាពផ្លូវចិត្ត សម្រាប់បុគ្គលិកអប់រំ និងសិស្សានុសិស្ស។ ដូចនេះ សាលារៀនត្រូវ៖

  – ១) បង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន
  – ២) កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាពដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា បរិស្ថានសាលារៀនបៃតង សាលាស្អាតគ្មានសំរាម
  – ៣) លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ ផ្តោតលើទឹកទទួលទាន កន្លែងលាងដៃ បង្គន់   អនាម័យ ការពាក់ម៉ាស និងការរក្សាគម្លាត
  – ៤) លើកកម្ពស់អាហារូបត្ថម្ភ ដោយផ្តោតលើសុវត្ថិភាពចំណីអាហារ ការផ្តល់អាហារតាមសាលារៀន និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ
  – ៥) អប់រំអំពីសុខភាពសិក្សា និងគន្លងប្រក្រតីភាពថ្មី ដោយអនុវត្តតាមខ្លឹមសារនៃកម្មវិធីសិក្សាមុខវិជ្ជា សុខភាពសិក្សា និងការហាត់ប្រាណ និងលេងកីឡា។

# អាទិភាពស្នូលទី៤

# ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ

# ការចូលរួមរបស់សហគមន៍

– ចេញគោលការណ៍ឱ្យសាលារៀនអាចបង្កើត "មូលនិធិសមធម៌" ដើម្បីប្រើប្រាស់ថវិកាបដិភាគពីមាតាបិតាសិស្សសម្រាប់គាំទ្រដល់ការបន្ថែមមុខវិជ្ជាថ្មីៗ ក៏ដូចជាការរៀបចំកម្មវិធីជួយសិស្សរៀនយឺត ការបង្កើតក្លឹបសិក្សា នៅតាមសាលាដែលមានសក្តានុពល ព្រមទាំងកាត់បន្ថយការបង្រៀនគួរ

– ដាក់ចេញគោលនយបាយដើម្បីជំរុញ "ភាពជាដៃគូសាធារណៈនិងសហគមន៍ក្នុងការអប់រំ" ដោយចាប់ផ្តើមអនុវត្តនៅតាមសាលារៀនគំរូ និងរៀបចំសេចក្តីណែនាំអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សា រួមទាំងរៀបចំយន្តការថ្នាក់ជាតិចុះជួយជំរុញនៅទូទាំងប្រទេស ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ជាពិសេសការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស

– លើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការសាងសង់ និងជួសជុលអគារសិក្សា ដោយកំណត់អាទិភាពថវិកាជាតិទៅលើការសាងសង់ផ្ទះគ្រូនៅតំបន់ដាច់ស្រយាល និងជួបការលំបាក។

# បន្ថែមពីលើអាទិភាពស្នូលទាំង ៤
# ក្រសួងបានកំណត់អាទិភាព ៤ បន្ថែមទៀត

- អាទិភាពស្នូលទី៥ ៖ ការអប់រំឱ្យជីជលម
- អាទិភាពស្នូលទី៦ ៖ ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា
- អាទិភាពស្នូលទី៧ ៖ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព
- អាទិភាពស្នូលទី៨ ៖ ការអភិវឌ្ឍការអប់រំកាយ និងកីឡា

# អាទិភាពស្នូលទី៥ ៖ ការអប់រំឌីជីថល

នៅក្នុងដំណាក់កាលកូវីដ កម្ពុជាបានដើរទៅមុខ ១០ឆ្នាំមុនកាលកំណត់ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ។ គ្រូបង្រៀនបានខិតខំរៀនពីការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបង្រៀនសិស្ស នៅពេលសាលាត្រូវបានផ្អាកដំណើរការជាបណ្ដោះអាសន្ន។ ដូចនេះ ក្រសួងនឹងបន្តលើកកម្ពស់ការអប់រំឌីជីថល តាមរយៈ ៖

- ១) លើកកម្ពស់អក្ខរកម្មឌីជីថល៖ បញ្ជ្រាបអក្ខរកម្មឌីជីថល ទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា និងគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ។
- ២) លើកកម្ពស់ការអប់រំឌីជីថល៖ បន្តអនុវត្តមុខវិជ្ជាឌីជីថល ដូចជាការសរសេរកូដ ការផលិតមនុស្សយន្ត ។ល។ នៅសាលារៀនជំនាន់ថ្មី និងដាក់ឱ្យអនុវត្តនៅតាមវិទ្យាល័យធនធាន វិទ្យាល័យ ចំណេះទូទៅនិងបច្ចេកទេស និងវិទ្យាល័យដែលមានសក្ដានុពល ដោយសហការជាមួយគ្រឹះស្ថាន ឧត្ដមសិក្សា និងផ្នែកឯកជន។

# អាទិភាពស្នូលទី៥ ៖ ការអប់រំឌីជីថល

- ៣) កសាងជំនាញផ្នែកឌីជីថលនៅកម្រិតឧត្តមសិក្សា៖ បង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលមានស្រាប់ ដោយផ្តល់អាហារូបករណ៍ដល់ការបណ្តុះបណ្តាលសាស្ត្រាចារ្យផ្នែកឌីជីថលនៅក្រៅប្រទេស ការបង្កើតអាហារូបករណ៍ផ្នែកបច្ចេកវិទ្យាឌីជីថលដល់និស្សិតឆ្នើម ដោយសហការជាមួយផ្នែករដ្ឋ និងផ្នែកឯកជន
- ៤) ធ្វើបច្ចុប្បន្នកម្មទេពកោសល្យជំនាញឌីជីថល៖ សហការជាមួយក្រសួង ដៃគូក្រុមហ៊ុនពាក់ព័ន្ធ
- ៥) គាំទ្រដល់វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យខាងផ្នែកឌីជីថល៖ ផ្តល់ថវិកាគាំទ្រ និងអាហារូបករណ៍ដល់ វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ក្នុងការបណ្តុះបណ្តាលជំនាញឌីជីថល។

# អាទិភាពស្នូលទី៥ ៖ ការអប់រំឌីជីថល

– រៀបចំបង្កើតបន្ទប់រៀនឌីជីថលនៅតាមសាលារៀន ដោយបំពាក់សម្ភារអប្បបរមា រួមមាន LCD Projector/ Smart TV, Smartboard, អ៊ីនធើណិត
– ជំរុញការអនុវត្តការរៀននិងបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា ដើម្បីធានាថាសិស្សថ្នាក់ទី៤-៦ បានសិក្សាភាសាអង់គ្លេសស្របតាមកម្មវិធីសិក្សា
– ផ្តល់ការអប់រំចំណេះដឹងជាមូលដ្ឋានគ្រឹះសម្រាប់ការអប់រំដោយឆ្លើយតបជាមួយយុគ្គសម័យបច្ចេកវិទ្យា តាមរយៈការធ្វើកំណែទម្រង់សាលារៀន និងកំណែទម្រង់ការបណ្តុះបណ្តាលគ្រូ ដោយធ្វើ យ៉ាងណាឱ្យភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់ផ្នែកបច្ចេកវិទ្យា និងការអនុវត្តវិធីសាស្រ្តបង្រៀន ដោយប្រើប្រាស់បច្ចេកវិទ្យាដូចជា ការផ្តល់សម្ភារៈឧបទេស និងការបណ្តុះបណ្តាលដល់គ្រូ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការបង្រៀនសិស្ស។

# អាទិភាពស្នូលទី៦ ៖
# ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

- ១) គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តោតលើការពង្រឹងអភិបាលកិច្ច, ការលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យ ឱ្យមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត
- ២) កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការជំរុញការសិក្សា ការបណ្តុះបណ្តាល និងកសាង ជំនាញផ្នែកឌីជីថលនៅថ្នាក់ឧត្តមសិក្សា និងនៅគ្រប់កម្រិតបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងជំរុញការកែលម្អកម្មវិធីសិក្សា ដើម្បីបន្សុីគ្នារវាងតម្រូវការជំនាញ និងការបណ្តុះបណ្តាល
- ៣) រៀបចំ និងអនុវត្តកម្មវិធី និង/ឬ គំនិតផ្តួចផ្តើម ថ្នាក់ជាតិ ក្នុងការអភិវឌ្ឍ និងការបណ្តុះបណ្តាល ធនធានមនុស្សដែលមានទេពកោសល្យឌីជីថល រួមមានជាអាទិ៍ ការបង្កើតមូលនិធិថ្នាក់ជាតិ សម្រាប់ផ្តល់អាហារូបករណ៍លើផ្នែកបច្ចេកវិទ្យាឌីជីថល ទាំងក្នុង និងក្រៅប្រទេស ដោយកៀរគរ ការធ្វើសហហិរញ្ញប្បទានពីវិស័យសាធារណៈ វិស័យឯកជន និងគ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាល

# អាទិភាពស្នូលទី៦ ៖
# ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

– ៤) រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និងការបណ្តុះគំនិតថ្មី ដោយផ្អែកលើតម្រូវការជំនាញថ្មី (New skills Requirement)
– ៥) ជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ផ្អែកឌីជីថល នៅតាមបណ្តាសាកលវិទ្យាល័យ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ វិទ្យាស្ថាននិងមជ្ឈមណ្ឌល ស្រាវជ្រាវនានា តាមរយៈការចងក្រងជាប្រព័ន្ធនូវបណ្តាស្ថាប័ន-គ្រឹះស្ថានស្រាវជ្រាវ
– ៦) កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និងការអភិវឌ្ឍការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍ រួមមានជាអាទិ៍ ការរៀបចំឱ្យមានបណ្តុះមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល ដើម្បីជំរុញការផ្លាស់ប្តូរទិន្នន័យ, ព័ត៌មាន និងចំណេះដឹង គួបផ្សំនឹងការរៀបចំ មូលនិធិថវិកាគាំទ្រ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

# អាទិភាពស្នូលទី៦ ៖
# ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

យុទ្ធសាស្ត្រកំណែទម្រង់ការអប់រំឧត្តមសិក្សាឆ្ពោះទៅរកឧត្តមភាព ៖

– (១) ការធ្វើទំនើបកម្មកម្មវិធីសិក្សា, វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃ
– (២) ការលើកកម្ពស់សមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍
– (៣) ការកែលម្អសមធម៌ និង គុណភាព
– (៤) ការលើកកម្ពស់អន្តរជាតូបនីយ៍កម្មឧត្តមសិក្សា
– (៥) ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចស្ថាប័ន
– (៦) ការពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង
– (៧) ការអភិវឌ្ឍសមត្ថភាព

# អាទិភាពស្នូលទី៧ ៖ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព

- អនុវត្តអភិក្រមស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផលឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអនុវិស័យ
- ពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ ដោយត្រូវរួមបញ្ចូលគ្នានូវការពិនិត្យឡើងវិញមុខងារនិងភារកិច្ច, ការរៀបចំផែន ការប្រចាំឆ្នាំ, ការអនុវត្តគន្លងអាជីព, ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យតាមដាននិងវាយតម្លៃ
- ពង្រឹងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ដោយត្រូវផ្តោតលើការបណ្តុះ-បណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន, ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង និងជាអ្នកស្រាវជ្រាវ និងវាយតម្លៃ, ការកែលម្អប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍគន្លងអាជីព
- វាយតម្លៃនាយកសាលាល្អ គ្រូបង្រៀនល្អ គ្រូបង្រៀនល្អភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង និងសាលារៀនស្អាតជាដើម ដោយប្រើប្រាស់ប្រព័ន្ធវង្វាយតម្លៃការបំពេញការងារប្រចាំឆ្នាំ និងការពង្រឹងប្រព័ន្ធនិងផ្លាស់ប្តូររបៀបធ្វើការ។

# អាទិភាពស្នូលទី៨ ៖ ការអភិវឌ្ឍការអប់រំកាយ និងកីឡា

– បន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ, កាយសម្បទាមាំមួន, ឆន្ទៈមោះមុត, អំណត់ព្យាយាម, មានវិន័យ, មានស្មារតីក្រុម, គំនិតច្នៃប្រឌិត, និង មានការតស៊ូស្វិតស្វាញ សំដៅដណ្តើមបានលទ្ធផលល្អប្រសើរ ក្នុងការប្រកួតកីឡាលើឆាកអន្តរជាតិ និងមាន ជីវភាពរស់នៅស្របតាមពាក្យស្លោក "កីឡារស់ប្រកបដោយសុខដុមរមនាក្នុងសង្គមក្រោម ម្លប់សន្តិភាព" ព្រមទាំងបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"

# អាទិភាពស្នូលទី៨ ៖ ការអភិវឌ្ឍការអប់រំកាយ និងកីឡា

- ជំរុញការអនុវត្តកំណែទម្រង់ស៊ីជម្រៅវិស័យអប់រំកាយ និងកីឡា តាមរយៈការពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា, ការពង្រឹងយន្តការដែលមានស្រាប់ រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្តដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក, និងការពង្រឹងគុណភាពនៃការប្រកួតគ្រប់កម្រិត តាមរយៈការពង្រឹងសហព័ន្ធកីឡាជាតិ ការពង្រឹងការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា ការពង្រឹងការអនុវត្ត កម្មវិធីកីឡាក្រៅម៉ោងសិក្សា
- ជំរុញការលើកទឹកចិត្ត និងបណ្តុះវប្បធម៌អប់រំកាយ និងកីឡា ដល់ប្រជាជនឱ្យយល់ដឹងអំពីសារៈសំខាន់នៃការហាត់ប្រាណ និងលេងកីឡាជាប្រចាំ ដើម្បីសុខភាពផ្សារភ្ជាប់ទៅនឹងកិច្ចការសង្គម វប្បធម៌ ឈានទៅចូលរួមលុបបំបាត់ភាពអសកម្មផ្សេងៗក្នុងសង្គម ដើម្បីឱ្យប្រជាជនរស់នៅប្រកបដោយ ភាពស៊ីវិល័យ និងសុខដុមនីយកម្មក្នុងសង្គម។

# ផ្នែកទី៣ ៖ ស្តង់ដាសាលារៀនគំរូ ពានរង្វាន់សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី



កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ រាជរដ្ឋាភិបាល បានឯកភាពជាគោលការណ៍ ជូនក្រសួងអប់រំ យុវជន និងកីឡា **អនុវត្តស្តង់ដាសាលារៀនគំរូ និងពានរង្វាន់សម្តេចមហាបវរធិបតី ចាប់ពីឆ្នាំសិក្សា២០២៣-២០២៤។**


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ១០០៥ ស.ជ.ណ.ស.ប

ថ្ងៃ អង្គារ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសូមគោរពស្នើសុំគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់ ដើម្បីរៀបចំ«ពានរង្វាន់សាលាគំរូ **សម្តេចមហាបវរធិបតី**» សម្រាប់ការប្រារព្ធ «ទិវាគ្រូបង្រៀន ៥ តុលា»។

**យោង** ៖- លិខិតលេខ៥៨៩៩ អយក.រប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា

- លិខិតលេខ០២២ ខន/០២៣ សជណ របស់ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២៣
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមបណ្ឌិតសភាចារ្យជ្រាបថា រាជរដ្ឋាភិបាលឯកភាពជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា អនុវត្ត "**ស្តង់ដាសាលារៀនគំរូ**" និង "**ពានរង្វាន់សាលាគំរូ សម្តេចមហាបវរធិបតី**" ចាប់ពីឆ្នាំសិក្សា២០២៣-២០២៤ តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមបណ្ឌិតសភាចារ្យជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**អ៊ីន ចិរជាតិ**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

# លក្ខណៈសម្បត្តិសាលារៀនគំរូ

- ក).សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេច បានស្តង់ដាសាលារៀនគំរូ,
- ខ).សាលារៀនមានស្វ័យភាព ក្នុងការកសាងនិងអនុវត្តផែនការកែលម្អសាលារៀន និងថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រងនិងគ្រូបង្រៀន,
- គ).សិស្សត្រូវបានធ្វើតេស្ត ស្តង់ដាប្រកបដោយតម្លាភាពនិងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀននិងរៀន, ការជួយសិស្សរៀនយឺត, និងផ្តល់ព័ត៌មានដល់មាតាបិតាឬអាណាព្យាបាលនិងសហគមន៍,
- ឃ).គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀននិងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ,
- ង).មាតាបិតាឬអ្នកអាណាព្យាបាលនិង សហគមន៍ចូលរួមគាំទ្រនិងអភិវឌ្ឍសាលារៀន។

# ស្តង់ដាសាលារៀនគំរូ ៥

ស្តង់ដាសាលារៀនគំរូចំនួន ៥ សម្រាប់មត្តេយ្យសិក្សារហូតដល់មធ្យមសិក្សា ៖

– ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស
– ស្តង់ដាទី២៖ ការបង្រៀននិងរៀន
– ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍
– ស្តង់ដាទី៤៖ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន
– ស្តង់ដាទី៥ ៖ គណនេយ្យភាពរបស់សាលារៀន

# ស្តុចនាទី១៖ លទ្ធផលសិក្សារបស់សិស្ស

សូចនាករសំខាន់ៗ ៖

- **១. ការប្រមូលកុមារចូលរៀន៖** ភាគរយកុមារអាយុ ៣ឆ្នាំ, ៤ឆ្នាំ, ៥ឆ្នាំ បានចូលរៀន, អត្រាពិតនៃការសិក្សានៅបឋមសិក្សា, ភាគរយកុមារចូលរៀនត្រូវតាមអាយុ
- **២. កុមាររៀនបានគង់វង្សក្នុងសាលារៀន៖** អត្រាត្រួតថ្នាក់ថយចុះ, អត្រាបោះបង់ការសិក្សាថយចុះ
- **៣. លទ្ធផលនៃការសិក្សារបស់សិស្ស៖** ភាគរយកុមារអាយុ ៣ឆ្នាំ, ៤ឆ្នាំ, ៥ឆ្នាំ មានការអភិវឌ្ឍផ្នែកទាំង ៥, ភាគរយសិស្សសម្រេចបាននិទ្ទេស A, B, C លើមុខវិជ្ជា ភាសាខ្មែរ, គណិតវិទ្យា និងស្ទែម , ភាគរយសិស្សថ្នាក់ទី៣មានសមត្ថភាពអានតាមស្តង់ដា (៤៥ទៅ៦០ពាក្យក្នុងមួយនាទី), ភាគរយសិស្សថ្នាក់ទី៦មានសមត្ថភាពអានតាមស្តង់ដា (១០០ទៅ១២០ពាក្យក្នុងមួយនាទី), ភាគរយសិស្សជាប់តេស្តស្តង់ដាថ្នាក់ទី៣និងទី៦, ភាគរយសិស្សថ្នាក់ទី៧មានសមត្ថភាពអានតាមស្តង់ដា (១០០ទៅ១២០ពាក្យក្នុងមួយនាទី), ភាគរយសិស្សថ្នាក់ទី៩ មានសមត្ថភាពអានតាមស្តង់ដា (២០០ទៅ២៥០ពាក្យក្នុងមួយនាទី), ភាគរយសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬ មធ្យមសិក្សាទុតិយភូមិ។

# ស្តង់ដាទី១៖ លទ្ធផលសិក្សារបស់សិស្ស

សូចនាករសំខាន់ៗ ៖

- **៤. ស្ថានភាពអាហារូបត្ថម្ភរបស់សិស្ស៖** ភាគរយកុមារមានស្ថានភាពអាហារូបត្ថម្ភប្រសើរឡើង, សាលារៀនបានរៀបចំកម្មវិធីអាហារពេលព្រឹក ឬ អាហារសម្រន់សម្រាប់កុមារប្រកបដោយ គុណភាព, ភាគរយសិស្សក្រីក្រទទួលបានអាហារូបករណ៍ ឬការឧបត្ថម្ភនានា
- **៥. សីលធម៌ និងឥរិយាបថរបស់សិស្ស៖** ចំនួនកុមារទទួលរងអំពើហិង្សាបានថយចុះ, ការបញ្ចូលពិន្ទុ សីលធម៌និងឥរិយាបថសិស្សទៅក្នុងពិន្ទុរួម, ចំនួននិងភាគរយសិស្សទទួលបានមូលវិចារណ៍ល្អលើ ផ្នែកវិន័យ សីលធម៌ និងឥរិយាបថ។

# ស្តង់ដាទី២៖ ការបង្រៀន និងរៀន

សូចនាករសំខាន់ៗ ៖

- **១. ការអនុវត្តវិធីសាស្រ្តបង្រៀនថ្មី៖**សាលារៀនបានអនុវត្តវិធីសាស្រ្តរៀនតាមរយៈការលេង (Learning through Play), ភាគរយគ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ អនុវត្តកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង គណិតវិទ្យាដំបូងកម្រិតទី៣, ភាគរយសិស្សបានធ្វើកិច្ចការជាគម្រោង
- **២. ការអនុវត្តកម្មវិធីសិក្សានិងការរៀបចំផែនការបង្រៀន៖** សាលារៀនមានរៀបចំបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែតាមមុខវិជ្ជា និងរៀបចំផែនការបង្រៀនប្រចាំថ្ងៃ, ចំនួនគ្រូបង្រៀនអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវ, គ្រូបង្រៀនបានធ្វើបច្ចុប្បន្នកម្មកិច្ចតែងការបង្រៀនត្រឹមត្រូវ និងបានអនុវត្តទៀងទាត់, សាលារៀនបានប្រជុំវាយតម្លៃការអនុវត្តកម្មវិធីសិក្សាប្រចាំឆមាស និងប្រចាំឆ្នាំ, ភាគរយថ្នាក់រៀនមានផែនការបង្រៀនប្រចាំឆ្នាំតាមមុខវិជ្ជា, ភាគរយគ្រូអវត្តមាន, ភាគរយសិស្សអវត្តមាន, ចំនួនថ្ងៃសាលារៀនបិទទ្វារ

# ស្តង់ដារទី២៖ ការបង្រៀន និងរៀន

សូចនាករសំខាន់ៗ ៖

- **៣. សម្ភារៈរៀននិងបង្រៀន៖** ផលធៀបសិស្ស-សៀវភៅសិក្សាគោល, ភាគរយសិស្សមានសៀវភៅសិក្សាគោលមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម, ភាគរយនៃការបើកដំណើរការបន្ទប់កុំព្យូទ័រតាមផែនការ, ភាគរយនៃការបើកដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រទាំង៤តាមផែនការ, ដំណើរការ គាំទ្រ និងអភិវឌ្ឍបន្ទប់ពហុបំណង
- **៤. ការជួយគាំទ្រសិស្ស៖** ភាគរយសិស្សបានធ្វើកិច្ចការផ្ទះនិងមានការកែពីគ្រូ, ចំនួននិងភាគរយថ្នាក់រៀនមានក្លឹបស្វ័យសិក្សាមានដំណើរការ
- **៥. ដំណើរការបណ្ណាល័យ៖** សាលារៀនបានរៀបចំបណ្ណាល័យត្រឹមត្រូវ និងបានដំណើរការជាប្រចាំ,
- **៦. ការធ្វើអធិការកិច្ចផ្ទៃក្នុង៖** នាយកសាលារៀនបានចុះធ្វើអធិការកិច្ចផ្ទៃក្នុងតាមផែនការ, ភាគរយគ្រូបង្រៀនទទួលបានការផ្តល់ប្រឹក្សាគរុកោសល្យ/អធិការកិច្ចផ្ទៃក្នុងយ៉ាងតិចម្តងក្នុង១ឆ្នាំ

# ស្តង់ដាទី២៖ ការបង្រៀន និងរៀន

- **៧. ការប្រជុំបច្ចេកទេស៖**គ្រូបង្រៀនបានប្រជុំបច្ចេកទេសទៀងទាត់តាមផែនការរបស់សាលារៀន
- **៨. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្អាត៖** សាលារៀនមានសួនកុមារនិងសម្ភារៈសម្រាប់កុមារលេងដោយ សេរីនិងមានសុវត្ថិភាព, សាលារៀនទទួលបានពិន្ទុតាមរយៈឧបករណ៍វាយតម្លៃសាលារៀនស្អាត, សាលារៀននិងថ្នាក់រៀនមានផែនការសកម្មភាពកែលម្អបរិស្ថានថ្នាក់រៀន សាលារៀន និងភូមិ ផ្តោតលើការដាំដើមឈើ និងរៀបចំសួនបន្លែសម្រាប់គ្រួសារ
- **៩. ការអនុវត្តកម្មវិធីសិក្សាក្រៅម៉ោងសិក្សា៖** ភាគរយថ្នាក់ទី៤-៦ មានបង្រៀនភាសាបរទេស, ចំនួនដងសិស្សថ្នាក់ទី៤-៦រៀនកុំព្យូទ័រ, ភាគរយសិស្សថ្នាក់ទី៤-៦ រៀនសូត្របំណិនជីវិតមូលដ្ឋាន, ភាគរយសិស្សបានសន្សំប្រាក់ដើម្បីបន្តការសិក្សានៅមធ្យមសិក្សា, ចំនួននិងភាគរយសិស្សរៀនសូត្របំណិន កសិកម្មនិងបច្ចេកទេសដើម្បីរកចំណូល, ចំនួននិងភាគរយសិស្សបានសន្សំប្រាក់ និងសម្រេចចិត្តទៅរៀននៅឧត្តមសិក្សាតាមបំណងប្រាថ្នា

# ស្តង់ដាទី២៖ ការបង្រៀន និងរៀន

## – ១០. ការអនុវត្តការអប់រំសីលធម៌ ចរិយាធម៌៖

- *សាលារៀនបានអនុវត្តកម្មវិធីលើកកម្ពស់ចរិយាធម៌ (ស្អាត សុភាព របៀប ទៀងពេល និងសមាធិ)*
- *សាលារៀនមានសកម្មភាពកីឡា (មានតារាងនិងសិស្សលេងបាល់ទះ មានតារាងនិងសិស្សលេងបាល់ទាត់ មានតារាងនិងសិស្សលេងបាល់បោះ មានតារាងនិងសិស្សលេងវាយសី...)*
- *សាលារៀនមានសកម្មភាពអប់រំសិល្បៈ (ចម្រៀង គំនូរ របាំ តន្ត្រី)*
- *សាលារៀនបានអនុវត្តកម្មវិធីអភិវឌ្ឍយុវជន៖ ដំណើរការរបស់ក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន,*
- *កម្មវិធីមិត្តអប់រំមិត្ត និងកម្មវិធី ៣ល្អ, កម្មវិធីប្រកួតប្រជែងវោហាស័ព្ទ និងជជែកដេញដោល, កម្មវិធីសិល្បៈ និងកីឡា, កម្មវិធីស្ម័គ្រចិត្តក្នុងសហគមន៍, កម្មវិធីបរិស្ថាន និងការសម្អាតសាលារៀន, កម្មវិធីបោះជំរំ, ក្លឹបសិក្សា ស្វ័យសិក្សា និងកម្មវិធីជួយសិស្សរៀនយឺត, កម្មវិធីសប្បុរសធម៌ ។ល។*

# ស្តង់ដាទី៣៖ ការចូលរួមរបស់សហគមន៍

សូចនាករសំខាន់ៗ ៖

- **១. ការបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន៖** ចំនួនសមាសភាពគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស.), ភាគរយថ្នាក់រៀនបង្កើតនិងដំណើរការគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ.), ការប្រជុំប្រចាំត្រីមាស ឆមាស និងឆ្នាំដែលដឹកនាំដោយ គ.គ.ស., ភាគរយគ្រូបង្រៀនបានទទួលការសម្រេចចិត្តពី គ.គ.ស. លើការវាយតម្លៃ ការអនុវត្តការងារប្រចាំឆ្នាំ, ចំនួននាយកនិងនាយករងបានទទួលការសម្រេចចិត្តពី គ.គ.ស. លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ
- **២. ការចូលរួមរបស់សហគមន៍៖** ព័ត៌មាននានាត្រូវបានអនុម័តដោយ គ.គ.ស. និងបិទផ្សាយជាសាធារណៈ, សហគមន៍បានចូលរួមប្រជុំទៀងទាត់តាមផែនការ, សហគមន៍ចូលរួមរៀបចំបរិស្ថានបៃតង អនាម័យ អគារសិក្សា បន្ទប់រៀន សង្ហារិម និងបរិក្ខារសិក្សា, សាលារៀនមានកិច្ចសហប្រតិបត្តិការភាពជាដៃគូវិនិយោគជាមួយវិស័យសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍ, មាតាបិតាឬអ្នកអាណាព្យាបាលចូលរួម អនុវត្តកម្មវិធីអប់រំទៀងទាត់
- ៣. ការគាំទ្ររបស់សហគមន៍៖ បរិមាណចំណូលមូលនិធិបង់ចូលសាលារៀន, សហគមន៍បានធ្វើសកម្មភាពជួយកុមារនៅតាមផ្ទះ, ចំនួននិងភាគរយគ្រួសារទទួលរងអំពើហឹង្សាថយចុះ។

# ស្តង់ដាទី៤៖ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

សូចនាករសំខាន់ៗ ៖

- **១. ការគ្រប់គ្រងទូទៅនិងរដ្ឋបាល រួមទាំងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន៖** សាលារៀន មានរចនាសម្ព័ន្ធរដ្ឋបាលគ្រប់គ្រងត្រឹមត្រូវ, សាលារៀនមានប្រព័ន្ធគ្រប់គ្រប់ទិន្នន័យស្ថិតិអប់រំច្បាស់លាស់ (បុគ្គលិក សិស្ស និងសារពើភណ្ឌ), សាលារៀនប្រើប្រាស់App សម្រាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យសាលារៀន, ភាគរយគ្រូលើស-ខ្វះ
- **២. ការរៀបចំផែនការអភិវឌ្ឍសាលារៀន៖** សាលារៀនបានកំណត់ចក្ខុវិស័យ បេសកកម្ម យុទ្ធសាស្ត្រ និងសកម្មភាពគន្លឹះ, សាលារៀនមានរបាយការណ៍ប្រចាំឆ្នាំត្រឹមត្រូវ, ផែនការសាលារៀន(៦ឆ្នាំ ៣ឆ្នាំ និង១ឆ្នាំ)បានរៀបចំតាមការណែនាំ
- **៣. ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក៖** ភាគរយគ្រូបង្រៀនបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ, ចំនួននាយកសាលានិងនាយករងបានចុះកិច្ចព្រមព្រៀងលទ្ធផលការងារប្រចាំឆ្នាំ, គ្រូបង្រៀនត្រូវបានវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ, ភាគរយគ្រូបង្រៀនចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពប្រចាំឆ្នាំ (កញ្ចប់ សម្ភារៈអំណាននិងគណិតវិទ្យាថ្នាក់ដំបូង ការប្រឹក្សាគរុកោសល្យ វិធីសាស្ត្របង្រៀន ការអប់រំវិន័យបែបវិជ្ជមាន វិធីសាស្ត្រអំណានក្នុងបណ្ណាល័យ...), ចំនួនដងទស្សនកិច្ចសិក្សាសម្រាប់គ្រូ ទៅសាលាផ្សេងក្នុងមួយឆ្នាំ

# ស្តង់ដារទី៤៖ ដំណើរការប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

- ៤. **រង្វាយតម្លៃលទ្ធផលសិក្សា៖** សាលារៀនបានរៀបចំការវាយតម្លៃលទ្ធផលសិក្សាកុមារតាមកម្មវិធីសិក្សា, ការធ្វើតេស្តស្តង់ដាដើមឆ្នាំ ប្រចាំខែ និងត្រីមាសបានរៀបចំទៀងទាត់, ចំនួនខែដែលបានជួយសិស្សរៀនយឺតផ្អែកតាមលទ្ធផលតេស្តស្តង់ដាប្រចាំខែ
- ៥. **ការលើកកម្ពស់សុខភាពសិក្សានិងអាហារូបត្ថម្ភរបស់សិស្ស៖** សាលារៀនមានបរិក្ខារទឹកស្អាត, អនាម័យ និងបន្ទប់ទឹក, សាលារៀនមានផ្តល់អាហារពេលព្រឹក, អាហារូបករណ៍
- ៦. **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ៖** សាលារៀនមានបណ្តាញអគ្គិសនី បំពាក់អ៊ីនធើណេតបន្ទប់កុំព្យូទ័រ បណ្ណាល័យ, ភាគរយ បន្ទប់រៀនបំពាក់ឧបករណ៍សិក្សាទំនើប (LCD, Smart TV, Smart Board...)។

# ស្តង់ដាទី៥៖ គណនេយ្យភាពរបស់សាលារៀន

សូចនាករសំខាន់ៗ ៖

– **១. វេទិកាសាធារណៈ៖** ការជួបប្រជុំមាតាបិតាសិស្ស (ទៅតាមប្រធានបទដូចជា ការណែនាំអំពីការកាត់បន្ថយនិងលុបបំបាត់អំពីហិង្សានៅក្នុងគ្រួសារនិងសាលារៀន, ការជំរុញការសិក្សារៀនសូត្រ, ការលើកកម្ពស់អាហារូបត្ថម្ភ, ការអប់រំអំពីគ្រឿងញៀន ច្បាប់ចរាចរ និង ការងារផ្សេងៗទៀត)

– **២. ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ៖** ការបង្ហាញលទ្ធផលសិក្សា, សាលារៀនបានផ្សព្វផ្សាយ សកម្មភាពប្រតិបត្តិនិងសមិទ្ធផលជាសាធារណៈ, ទិន្នន័យតេស្តវាយតម្លៃស្តង់ដាលើសមត្ថភាពសិស្សត្រូវបានអនុម័តនិងបិទផ្សាយ

– **៣. ការទទួលបានការគាំទ្រពីថ្នាក់ជាតិ៖** ចំនួនដងនាយកសាលានិងនាយករង បានទទួលការហ្វឹកហាត់ អនុវត្តការគ្រប់គ្រងតាមសាលារៀន, ភាគរយគ្រូបង្រៀនបានទទួលការហ្វឹកហាត់ការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង និង/ឬ វិធីសាស្ត្របង្រៀនភាសាខ្មែរ និងគណិតវិទ្យា, ក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចុះពិនិត្យតាមដាន និងផ្តល់ការគាំទ្រតាមផែនការ, នាយកសាលានិងនាយករងបានទទួលការហ្វឹកហាត់អនុវត្តកម្មវិធីសាលារៀនគំរូ, សាលារៀនទទួលការចុះជួយបច្ចេកទេសពីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមន្ទីរ។

